អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៨

# សេចក្តីប្រកាសព័ត៌មាន

## អង្គបុរេជំនុំជម្រះនឹងបើកសវនាការស្តាប់ទឡ្ហីករណ៍ពីភាគីនៅក្នុងសំណុំរឿង ០០៤/២

អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានទទួលបណ្តឹងឧទ្ធរណ៍ដាក់ដោយសហព្រះរាជអាជ្ញាជាតិនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ បណ្តឹងឧទ្ធរណ៍ដាក់ដោយសហមេធាវីការពារក្តីជនត្រូវចោទ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ ប្រឆាំងនឹងដីកាដំណោះស្រាយ(ដីកាបញ្ជូនទៅជំនុំជម្រះ) ដែលចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ នៅក្នុងសំណុំរឿង ០០៤/២ និងបណ្តឹងឧទ្ធរណ៍ដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ប្រឆាំងនឹងដីកាលើកលែងចោទប្រកាន់ជនត្រូវចោទដែលចេញដោយសហចៅក្រមស៊ើបអង្កេតជាតិនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ នៅក្នុងសំណុំរឿង ០០៤/២។

អង្គបុរេជំនុំជម្រះបានសម្រេចថា សវនាការនឹងត្រូវធ្វើឡើងនៅក្នុងសំណុំរឿង ០០៤/២ ដើម្បីស្តាប់ទឡ្ហីករណ៍ពីភាគីនៅក្នុងសំណុំរឿង មុនពេលដែលអង្គបុរេជំនុំជម្រះចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍ទាំងនោះ។ យោងតាមដីកាកំណត់កាលបរិច្ឆេទដែលបានចេញនៅថ្ងៃនេះ សវនាការនេះនឹងត្រូវធ្វើឡើងនៅថ្ងៃទី១៩ ថ្ងៃទី២០ និងថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩។

សំណៅជាសាធារណៈនៃដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការនេះអាចរកមើលបាននៅលើគេហទំព័រ៖
https://www.eccc.gov.kh/km/document/court-196

សហព្រះរាជអាជ្ញាជាតិ សហព្រះរាជអាជ្ញាអន្តរជាតិ និងសហមេធាវីជាតិ-អន្តរជាតិការពារក្តីជនត្រូវចោទនឹងមានសិទ្ធិលើកឡើងពីទឡ្ហីករណ៍របស់ខ្លួន។ ប្រសិនបើជនត្រូវចោទមានវត្តមាន ជនត្រូវចោទនឹងទទួលបានឱកាសដើម្បីធ្វើសេចក្តីសន្និដ្ឋានផ្ទាល់ខ្លួននៅពេលចុងបញ្ចប់បិទសវនាការ។

នៅពេលបិទបញ្ចប់សវនាការ អង្គបុរេជំនុំជម្រះនឹងធ្វើការពិចារណាដើម្បីចេញសាលដីកាសម្រេច។

អង្គបុរេជំនុំជម្រះនៃ អ.វ.ត.ក មានសមាសភាពចៅក្រមជាតិចំនួនបីរូប និងចៅក្រមអន្តរជាតិចំនួនពីររូប។ ក្នុងនាមជាអង្គជំនុំជម្រះដោះស្រាយបណ្តឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះ អាចបើកសវនាការលើសំណើ និងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា និងសេចក្តីសម្រេចដែលចេញដោយសហចៅក្រមស៊ើបអង្កេត។

សវនាការនេះនឹងធ្វើឡើងជាសាធារណៈនៅពេលដែលចាប់ផ្តើមឧទ្ទេសនាមភាគីនៅក្នុងសំណុំរឿងជូនអង្គជំនុំជម្រះ និងនៅពេលដែលអង្គជំនុំជម្រះអានសេចក្តីរាយការណ៍អំពីសំណុំរឿងនេះ។ បន្ទាប់មក អង្គបុរេជំនុំជម្រះនឹងស្តាប់ទឡ្ហីករណ៍ពីភាគីនៅក្នុងសំណុំរឿងនៅក្នុងសវនាការសម្ងាត់វិញ។ បណ្តាញសារព័ត៌មាន នឹងត្រូវបានអនុញ្ញាតឲ្យថតរូបជាផ្លូវការ បន្ទាប់ពីបិទបញ្ចប់សវនាការ។


*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងៈ*

លោក នេត្រ ភក្ត្រា

ប្រធានផ្នែកកិច្ចការសាធារណៈ និងជាមន្ត្រីនាំពាក្យ

ទូរស័ព្ទចល័ត+៨៥៥(0)១២៤៨៨១៥៦

ទូរស័ព្ទលើតុ: +៨៥៥(0)២៣៨៦១៥៦៤

អ៊ីមែល: neth.pheaktra@eccc.gov.kh